**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

**រាជរដ្ឋាភិបាលកម្ពុជា**

លេខ: ១៦៥ សសរ

# សេចក្តីសម្រេច

## ស្តីពី

## ការតែងតាំងសមាសភាពនៃគណៈកម្មការ សម្រាប់សិក្សា និងរៀបចំសាងសង់វិមាន អនុស្សាវរីយ៍ នយោបាយ ឈ្នះ ឈ្នះ និងការបញ្ចប់សង្គ្រាមស៊ីវិលនៅកម្ពុជា របស់សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា

## រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩១៣/៩០៣ ចុះថ្ងៃទី ២៤ ខែ កញ្ញា ឆ្នាំ ២០១៣ ស្តីពីការតែងតាំង រាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១២១៣/១៣៩៣ ចុះថ្ងៃទី ២១ ខែ ធ្នូ ឆ្នាំ ២០១៣ ស្តីពីការកែសម្រួល និងបំពេញបន្ថែមសមាសភាពរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញសេចក្តីសម្រេចលេខ ១៤០ សសរ ចុះថ្ងៃទី ០៩ ខែ តុលា ឆ្នាំ ២០១៤ ស្តីពីការបង្កើតគណៈកម្មការ សម្រាប់សិក្សា និងរៀបចំសាងសង់ស្តូបអនុស្សាវរីយ៍ នៃការបញ្ចប់សង្គ្រាមស៊ីវិលនៅកម្ពុជា តាមរយៈនយោបាយ ឈ្នះ ឈ្នះ របស់សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា
- យោងតាមការចាំបាច់

## សម្រេច

**ប្រការ១.-**

ត្រូវបានតែងតាំងសមាសភាពនៃគណៈកម្មការ សម្រាប់សិក្សា និងរៀបចំសាងសង់វិមានអនុស្សាវរីយ៍ នយោបាយ ឈ្នះ ឈ្នះ និងការបញ្ចប់សង្គ្រាមស៊ីវិលនៅកម្ពុជា ដូចខាងក្រោម ៖

| | | | |
|---|---|---|---|
| ១. ឯកឧត្តម | ទៀ បាញ់ | ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងការពារជាតិ | ប្រធាន |
| ២. ឯកឧត្តម | ទា ច័ន្ទលីដា | អនុរដ្ឋលេខាធិការ ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ | អនុប្រធាន |
| ៣. លោកជំទាវ | ឆាយ វ៉ាន់នឿន | រដ្ឋលេខាធិការ ទីស្តីការគណៈរដ្ឋមន្ត្រី | អនុប្រធាន |
| ៤. ឯកឧត្តម | ជូ វិជិត្ត | រដ្ឋលេខាធិការ ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ | អនុប្រធាន |



www.pheakdeylaw.com

| | | | |
|---|---|---|---|
| ៥. ឯកឧត្តម | ជា ប៉ូរ៉ា | រដ្ឋលេខាធិការ ក្រសួងទេសចរណ៍ | សមាជិក |
| ៦. ឯកឧត្តម | ផុច ភឿន | រដ្ឋលេខាធិការ ក្រសួងវប្បធម៌ និងវិចិត្រសិល្បៈ | សមាជិក |
| ៧. លោកជំទាវ | គង់ បញ្ញា | រដ្ឋលេខាធិការ ក្រសួងព្រះបរមរាជវាំង | សមាជិកា |
| ៨. នាយឧត្តមសេនីយ៍ | នេត សាវឿន | អគ្គស្នងការនគរបាលជាតិ | សមាជិក |
| ៩. នាយឧត្តមសេនីយ៍ | សៅ សុខា | មេបញ្ជាការកងរាជអាវុធហត្ថលើផ្ទៃប្រទេស | សមាជិក |
| ១០. ឯកឧត្តម | គុណ ញឹម | អគ្គនាយក គយ និងរដ្ឋាករកម្ពុជា | សមាជិក |
| ១១. ឯកឧត្តម | ប៉ា សុជាតិវង្ស | អភិបាល នៃគណៈអភិបាលរាជធានីភ្នំពេញ | សមាជិក |
| ១២. នាយឧត្តមសេនីយ៍ | ណឹម សុវត្ថិ | ទីប្រឹក្សា-នាយកខុទ្ទកាល័យឯកឧត្តម ឧបនាយករដ្ឋមន្ត្រី ទៀ បាញ់ និងជាអគ្គនាយក អគ្គនាយកដ្ឋាន នយោបាយ និងកិច្ចការបរទេស ក្រសួងការពារជាតិ | សមាជិកប្រចាំការ |
| ១៣. នាយឧត្តមសេនីយ៍ | សំ វណ្ណថន | អគ្គលេខាធិការ ក្រសួងការពារជាតិ | សមាជិក |
| ១៤. នាយឧត្តមសេនីយ៍ | ស៊ុំ សំណាង | អគ្គនាយក ភស្តុភារ-ហិរញ្ញវត្ថុ ក្រសួងការពារជាតិ | សមាជិក |
| ១៥. នាយឧត្តមសេនីយ៍ | មាស សាវ៉ន | អគ្គនាយក យោធសេវា ក្រសួងការពារជាតិ | សមាជិក |
| ១៦. នាយឧត្តមសេនីយ៍ | សែម សុវណ្ណនី | អគ្គនាយក មជ្ឈមណ្ឌលជាតិគ្រប់គ្រងកងកម្លាំងរក្សាសន្តិភាព បោសសំអាតមីន និងកាកសំណល់សង្គ្រាម | សមាជិក |
| ១៧. ឯកឧត្តម | ស៊ិន សំណាង | ទីប្រឹក្សារាជរដ្ឋាភិបាល | សមាជិក |
| ១៨. ឯកឧត្តម | យី ផន | នាយករង ខុទ្ទកាល័យសម្តេចតេជោ នាយករដ្ឋមន្ត្រី | សមាជិក |
| ១៩. ឧត្តមសេនីយ៍ឯក | ហ៊ុន ម៉ាណែត | មេបញ្ជាការរង កងទ័ពជើងគោក និងជាមេបញ្ជាការ បញ្ជាការដ្ឋានជាតិកម្លាំងពិសេសប្រឆាំងភេរវកម្ម | សមាជិក |
| ២០. ឧត្តមសេនីយ៍ទោ | ខឹម សុខ | នាយករង នាយកដ្ឋានវិស្វកម្ម ក្រសួងការពារជាតិ | សមាជិក ។ |

**ប្រការ២.-**

សមាសភាពនៃគណៈកម្មការសម្រាប់សិក្សា និងរៀបចំសាងសង់សាងសង់វិមានអនុស្សាវរីយ៍នយោបាយ ឈ្នះ ឈ្នះ និងការបញ្ចប់សង្គ្រាមស៊ីវិលនៅកម្ពុជា ត្រូវបំពេញភារកិច្ច ដូចមានចែងក្នុងសេចក្តីសម្រេច លេខ១៤០ សសរ ចុះថ្ងៃទី ០៩ ខែ តុលា ឆ្នាំ ២០១៤ ស្តីពីការបង្កើតគណៈកម្មការ សម្រាប់សិក្សា និងរៀបចំសាងសង់ស្តូបអនុស្សាវរីយ៍ នៃការបញ្ចប់សង្គ្រាមស៊ីវិលនៅកម្ពុជា តាមរយៈនយោបាយ ឈ្នះ ឈ្នះ ។

**ប្រការ៣.-**

បទប្បញ្ញត្តិទាំងឡាយណាដែលផ្ទុយនឹងសេចក្តីសម្រេចនេះ ត្រូវទុកជានិរាករណ៍ ។

**ប្រការ៤.-**

រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងការពារជាតិ រដ្ឋមន្ត្រីក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ រដ្ឋលេខាធិការ គ្រប់ក្រសួង និងប្រធានគ្រប់ស្ថាប័នពាក់ព័ន្ធ និងសាមីខ្លួនដូចមានចែងក្នុងប្រការ១ ត្រូវទទួលបន្ទុកអនុវត្តសេចក្តីសម្រេចនេះ ឲ្យមានប្រសិទ្ធភាពចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

ធ្វើនៅរាជធានីភ្នំពេញ, ថ្ងៃទី [illegible] ខែ [illegible] ឆ្នាំ ២០១៤

**នាយករដ្ឋមន្ត្រី**

**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន**

**កន្លែងទទួល ៖**
- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាធម្មនុញ្ញ
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- អគ្គលេខាធិការរាជរដ្ឋាភិបាល
- ខុទ្ទកាល័យសម្តេចតេជោ នាយករដ្ឋមន្ត្រី
- ខុទ្ទកាល័យ ឧបនាយករដ្ឋមន្ត្រី
- ដូចប្រការ ៤
- រាជកិច្ច
- ឯកសារ-កាលប្បវត្តិ



www.pheakdeylaw.com